ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

សាលាភូមិន្ទរដ្ឋបាល

លេខ....៧១៧.......ស.ភ.រ

# សេចក្តីជូនដំណឹង

សាលាភូមិន្ទរដ្ឋបាលសូមជម្រាបជូនដល់បេក្ខជនទាំងអស់ ដែលបានដាក់ពាក្យចូលរួមក្នុងការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០ មេត្តាជ្រាបថា ការប្រឡងលើវិញ្ញាសាសរសេរលើកទី១ នឹងប្រព្រឹត្តទៅដូចខាងក្រោម៖

- វិញ្ញាសា សរសេរលើកទី១ (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧)
  - ១- ពហុចម្លើយ (ពេលរសៀល៖ ១៣ម៉០០នាទី ដល់ម៉ោង ១៥ម៉០០នាទី)
  - ២- ភាសាអង់គ្លេស ឬភាសាបារាំង (ពេលរសៀល៖ ១៦ម៉០០នាទី ដល់ម៉ោង ១៧ម៉៣០នាទី)
- វិញ្ញាសា សរសេរលើកទី២ (ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៧)
  - ១- អធិប្បាយពាក់ព័ន្ធនឹងចំណេះដឹងទូទៅ
    (ពេលរសៀលថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៣ម៉០០នាទី ដល់ម៉ោង ១៦ម៉០០នាទី)
  - ២- វិញ្ញាសា ជំនាញ
    (ពេលរសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១២ម៉០០នាទី ដល់ម៉ោង ១៥ម៉០០នាទី)
  - ៣- ដោះស្រាយបញ្ហាតាមករណីសិក្សា
    (ពេលរសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង ១៦ម៉០០នាទី ដល់ម៉ោង ១៨ម៉០០នាទី)
- វិញ្ញាសា សួរផ្ទាល់មាត់ (ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ ចាប់ផ្តើមពេលព្រឹកម៉ោង ៧ម៉០០នាទី តទៅ)

បេក្ខជនត្រូវមកដល់សាលាភូមិន្ទរដ្ឋបាលឲ្យបាន១ម៉ោងមុនការប្រឡង ព្រមទាំងភ្ជាប់មកជាមួយ៖

១- សលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

២- ប៊ិចពណ៌ខៀវ បន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។

បេក្ខជនមិនត្រូវបានអនុញ្ញាតឱ្យយកឯកសារ ទូរស័ព្ទ ឧបករណ៍អេឡិចត្រូនិកផ្សេងៗចូលក្នុងមណ្ឌលប្រឡងជាដាច់ខាត។

បេក្ខជនអាចចូលទៅក្នុងគេហទំព័ររបស់សាលា www.era.gov.kh ដើម្បីទទួលព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការប្រឡងនេះ។

សេចក្តីដូចបានជូនដំណឹងខាងលើ សូមបេក្ខជនទាំងអស់ ជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៥កើត ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា គ.ស ២០១៧

**សាលាភូមិន្ទរដ្ឋបាល**

អាសយដ្ឋាន ៖ អគារលេខ ១៧ វិថីឧកញ៉ាញឹកតុំឡុង (៤៦៦) រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ និងទូរសារ ៖ (855) 23 215 408 / 023 997 658

អ៊ីម៉ែល ៖ era.rsa@gmail.com គេហទំព័រ ៖ www.era.cambodia.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ...៨៧៤...ស.ភ.រ

## សេចក្តីណែនាំ

## ដល់បេក្ខជនក្នុងពេលប្រឡង

បេក្ខជនទាំងពីរភេទចូលរួមប្រឡងប្រជែងជ្រើសរើសចូលរៀនជាសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០ នៅសាលាភូមិន្ទរដ្ឋបាល ត្រូវគោរព អនុវត្តតាមការណែនាំដូចតទៅ៖

- ត្រូវចូលមកមណ្ឌលប្រឡងតាមច្រកទ្វារខាងក្រោយ និងយកភ្ជាប់មកជាមួយនូវសលាកបត្រឯកត្តជន អត្តសញ្ញាណបណ្ណ ឬ លិខិតសំគាល់ខ្លួន ព្រមទាំង ប៊ិចខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង
- ហាមយកជាប់ជាមួយនូវឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។ សាលាមិនទទួលខុសត្រូវ រក្សាទុកនូវ ឯកសារ ទូរស័ព្ទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទទេ។
- ករណីមកយឺតម៉ោង "តិចជាង ១៥នាទី" ត្រូវសុំការអនុញ្ញាតពីប្រធានមណ្ឌលប្រឡងជាមុនទើបអាចចូលប្រឡងបាន និង ប្រគល់សន្លឹកកិច្ចការប្រឡងតាមម៉ោងកំណត់។ ការមកយឺតយ៉ាវលើស "១៥ នាទី" មិនអនុញ្ញាតឲ្យចូលប្រឡងដាច់ខាត។
- អវត្តមានមិនបានប្រឡងវិញ្ញាសាណាមួយ នឹងមិនត្រូវបានអនុញ្ញាតឲ្យប្រឡងវិញ្ញាសាបន្តបន្ទាប់ឡើយ។
- មិនត្រូវចូលបន្ទប់ប្រឡងមុនពេលហៅឈ្មោះ ត្រូវអង្គុយតាមលេខតុដែលបង្ហាញ ត្រូវសរសេរឈ្មោះ និងលេខតុលើក្បាល សន្លឹកកិច្ចការប្រឡងតាមការណែនាំរបស់អនុរក្ស និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញទោះបីជាក្រដាសប្រឡង គ្មានសរសេរចម្លើយ ឬដំណោះស្រាយអ្វីក៏ដោយ។ ការមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្ស ចាត់ទុកអវត្តមាន។
- មិនត្រូវសរសេរក្នុងសញ្ញាខ្វែងនៃគ្រប់ទំព័រសន្លឹកកិច្ចការប្រឡង និងមិនត្រូវធ្វើគំនូសសញ្ញាធ្វើឲ្យដឹងអាគតដ្ឋាននៃសន្លឹកកិច្ចការ ប្រឡងឡើយ។ មិនត្រូវធ្វើសកម្មភាពលួចចម្លងតាមគ្រប់រូបភាព ប៉ុនប៉ងលួចចម្លង ឬចែករំលែកព័ត៌មានដល់អ្នកដទៃ។
- បេក្ខជនត្រូវដឹងអំពីសញ្ញាកណ្តឹង៖
    + កណ្តឹងទី១៖ ចូលបន្ទប់ប្រឡងបំពេញក្បាលសន្លឹកកិច្ចការប្រឡង
    + កណ្តឹងទី២៖ ចាប់ផ្តើមធ្វើវិញ្ញាសា
    + កណ្តឹងទី៣៖ រំឭកថានៅសល់ ១៥នាទីទៀត ដល់ម៉ោងត្រូវប្រមូលសន្លឹកកិច្ចការប្រឡង
    + កណ្តឹងទី៤៖ ប្រគល់សន្លឹកកិច្ចការប្រឡងឲ្យអនុរក្សជាកំហិត។

បេក្ខជនដែលមិនគោរពប្រតិបត្តិតាមការណែនាំនានានេះ ឬគំរាមកំហែង ឬធ្វើឲ្យប៉ះពាល់ដល់កិត្តិយស បុរណភាពរូបរាងកាយ មន្ត្រីមានសមត្ថកិច្ចទាំងក្នុងបន្ទប់ប្រឡង និងក្រៅបន្ទប់ប្រឡង នឹងត្រូវបញ្ឈប់មិនឲ្យប្រឡងជាបន្ទាន់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្ត នេះ និងហាមឃាត់មិនឲ្យចូលរួមប្រឡងប្រជែងនៅសាលាភូមិន្ទរដ្ឋបាលជាអចិន្ត្រៃយ៍ ព្រមទាំងទទួលខុសត្រូវតាមផ្លូវច្បាប់ជាធរមាន។

គណៈមេប្រយោគ មានជំនឿយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវ និងចូលរួមថែរក្សាឲ្យបាននូវភាពរលូននៃដំណើរការប្រឡង របស់បេក្ខជន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំរកា ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០១៧

**គណៈមេប្រយោគ**

**ប្រធាន**

**ពេជ្រ ប៊ុនធិន**

អាសយដ្ឋាន : អាគារលេខ ១៧ វិថីឧកញ៉ាញឹកជូឡុង (៥៦៦)
រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ និងទូរសារ : (855) 23 215 408 / 023 997 658
អ៊ីមែល : era.rsa@gmail.com គេហទំព័រ : www.era.cambodia.gov.kh